# សង្គ្រាមនៅយូថាហ៍ និង ការសម្លាប់រង្គាលនៅភ្នំម៉េដូ

## ការកើនឡើងនូវភាពតានតឹងបាននាំទៅរកសង្គ្រាមនៅយូថាហ៍

បីឆ្នាំក្រោយពីអ្នកត្រួសត្រាយនៃពួកបរិសុទ្ធថ្ងៃចុងក្រោយដំបូងគេបានមកដល់ជ្រលងភ្នំសលត៍ លេក នោះរដ្ឋាភិបាលសហរដ្ឋបានរៀបចំដែនដីយូថាហ៍ និងបានចាត់តាំង ព្រិកហាំ យ៉ង់ ជាអភិបាលរដ្ឋទីមួយលើដែនដីនេះ ។ នៅពាក់កណ្ដាលឆ្នាំ ១៨៥៧ ថ្នាក់ដឹកនាំពួកបរិសុទ្ធថ្ងៃចុងក្រោយជាច្រើនបានឮពីពាក្យចចាមអារ៉ាមថា រដ្ឋាភិបាលសហពន្ធ័អាចដកព្រិកហាំ យ៉ង់ ហើយជំនួសអភិបាលថ្មីនៃដែនដីរដ្ឋ យូថាហ៍ដែលមានខ្នងបង្អែកដោយទាហានសហពន្ធ័ជាច្រើននាក់ ។ នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៨៥៧ ប្រធាន ព្រិកហាំ យ៉ង់ បាននៅជាមួយនឹងក្រុមពួកបរិសុទ្ធមួយដែលកំពុងប្រារព្ធខួបរំឭកលើកទី ១០ នៃការមកដល់របស់ពួកគេនៅក្នុងជ្រលងភ្នំសលត៍ លេកនេះ នៅពេលលោកបានទទួលការបញ្ជាក់អំពីដំណឹងពីមុននោះថា កងទព័មួយក្រុមកំពុងមកកាន់ទីក្រុង សលត៍ លេក ។

កាលពីប៉ុន្មានឆ្នាំមុន មានការមិនយល់ព្រម និងការខ្វែងគំនិតគ្នាដែលបន្សល់ទុកនូវការកើនឡើងនូវភាពតានតឹងរវាងពួកបរិសុទ្ធថ្ងៃចុងក្រោយ និងពួកមន្ត្រីរាជការនៃរដ្ឋាភិបាលសហរដ្ឋ ។ ពួកបរិសុទ្ធចង់បានអ្នកដឹកនាំដែលពួកគេបានជ្រើសរើស ហើយបានបដិសេធនូវការចាត់តាំងរបស់សហពន្ធ័ ដែលមិនបានឲ្យតម្លៃដល់ពួកគេ ហើយដែលអ្នកខ្លះមិនបានស្មោះត្រង់ ពុករលួយ និងគ្មានសីលធម៌សោះឡើយ ។ ពួកមន្ត្រីសហពន្ធ័ខ្លះបានជឿថាសកម្មភាព និងឥរិយាបថរបស់ពួកបរិសុទ្ធមានន័យថា ពួកគេកំពុងស្ថិតក្នុងការបះបោរប្រឆាំងនឹងរដ្ឋាភិបាលសហរដ្ឋ ។

ប្រធានសហរដ្ឋ ជេម ប៊ូខាណាន បានបញ្ជូនកងទព័ប្រមាណជា ២៥០០ នាក់ទៅកាន់ទីក្រុងសលត៍ លេក ដើម្បីអមដំណើរអភិបាលរដ្ឋថ្មីមួយប្រកបដោយសុវត្ថិភាពទៅរដ្ឋយូថាហ៍ ហើយដើម្បីបង្ក្រាបដល់ការបះបោរដែលមាននៅក្នុងចំណោមពួកបរិសុទ្ធ ជាអ្វីដែលលោកបានគិតនោះ ។ ការសម្រេចចិត្តនេះត្រូវបានធ្វើឡើងដោយគ្មានព័ត៌មានត្រឹមត្រូវអំពីស្ថានការណ៍នៅក្នុងរដ្ឋ យូថាហ៍ឡើយ ( សូមមើល *Church History in the Fulness of Times Student Manual,* បានកែសម្រួលលើកទីពីរ [ Church Educational System manual ឆ្នាំ ២០០៣ ] ទំព័រ ៣៦៨–៧១ ) ។

## ការរៀបចំដើម្បីការពារបូរណភាពដែនដី

នៅក្នុងទេសនកថាដល់ពួកបរិសុទ្ធ ប្រធាន យ៉ង់ និងអ្នកដឹកនាំសាសនាចក្រផ្សេងទៀតបានចាត់ទុកកងទ័ពដែលនឹងមកនោះថាជាសត្រូវ ។ ពួកគេបានភ័យខ្លាចថា ពួកកងទ័ពនោះអាចនឹងបណ្ដេញពួកបរិសុទ្ធចេញពីរដ្ឋយូថាហ៍ ដូចដែលពួកគេធ្លាប់ត្រូវបានគេបណ្ដេញចេញពីរដ្ឋអូហៃអូ មីសសួរី និងអិលលីណយពីមុនមក ។ ប្រធាន យ៉ង់ ដែលបានសុំឲ្យពួកបរិសុទ្ធសន្សំទុកគ្រាប់ធញ្ញជាតិជាច្រើនឆ្នាំមក បានផ្ដល់ការណែនាំថ្មីរបស់លោកដើម្បីឲ្យពួកគេនឹងមានអាហារបរិភោគ ប្រសិនបើពួកគេត្រូវរត់គេចពីកងទ័ពនេះ ។ ក្នុងនាមជាអភិបាលរដ្ឋយូថាហ៍ លោកក៏បានដឹកនាំឲ្យក្រុមជីវពលដែនដីរៀបចំការពារដល់បូរណភាពទឹកដីដែរ ។

## ជម្លោះជាមួយពួកអន្តោប្រវេសន៍ក្រុមរទេះសេះ

រុមរទេះសេះ ដែលធ្វើអន្តោប្រវេសន៍ បានធ្វើដំណើរមកភាគខាងលិចពីរដ្ឋអាកាន់សាសទៅកាន់រដ្ឋកាលីហ្វ័រញ៉ា បានចូលមករដ្ឋ យូថាហ៍ ចំពេលដែលពួកបរិសុទ្ធថ្ងៃចុងក្រោយកំពុងរៀបចំការពារដែនដី ប្រឆាំងនឹងការមកដល់នៃកងទ័ពរបស់សហរដ្ឋ ។ សមាជិកនៃក្រុមរទេះខ្លះបានរសាប់រសល់ ដោយសារតែពួកគេពិបាកនឹងទិញគ្រាប់ធុញ្ញជាតិដែលត្រូវការជាខ្លាំងពីពួកបរិសុទ្ធ ដែលត្រូវបានណែនាំឲ្យរក្សាគ្រាប់ធុញ្ញាជាតិនោះទុក ។ ពួកជនអន្តោប្រវេសន៍នោះក៏បានមានជម្លោះជាមួយនឹងពួកបរិសុទ្ធ ដែលមិនចង់ឲ្យសេះ និងសត្វគោជាច្រើនរបស់ពួកក្រុមរទេះនេះប្រើប្រាស់អាហារ និងធនធានទឹកដែលពួកបរិសុទ្ធត្រូវការសម្រាប់សត្វរបស់ពួកគេផ្ទាល់ដែរ ។

ទំនាស់បានផ្ទុះឡើងនៅទីក្រុងសេដា ជាទីតាំងចុងក្រោយគេនៅក្នុងរដ្ឋ យូថាហ៍តាមដងផ្លូវទៅកាន់រដ្ឋកាលីហ្វ័រញ៉ា ។ ការប្រឈមមុខជាច្រើនបានកើតឡើង រវាងសមាជិកនៃក្រុមរទេះខ្លះ និងពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ សមាជិកនៃក្រុមរទេះខ្លះបានគម្រាមកំហែងថានឹងចូលរួមក្នុងកងទ័ពរដ្ឋាភិបាលដែលកំពុងតែចេញដំណើរមកប្រឆាំងនឹងពួកបរិសុទ្ធ ។ ទោះបីជាមេបញ្ជាការនៃក្រុមរទេះនេះបានស្ដីបន្ទោសដល់ដៃគូរបស់លោកដោយសារបានធ្វើការគម្រាមកំហែងទាំងនេះក្ដី ក៏អ្នកដឹកនាំទីក្រុងសេដាខ្លះ និងអ្នករស់នៅទីនោះបានចាត់ទុកថាពួកអន្តោប្រវេសន៍នេះជាសត្រូវដែរ ។ ក្រុមរទេះនេះបានចាកចេញពីទីក្រុងក្រោយពីបានមកដល់តែត្រឹមប្រហែលមួយម៉ោងប៉ុណ្ណោះ ប៉ុន្តែប្រជាជន និងអ្នកដឹកនាំខ្លះនៅទីក្រុងសេដាចង់ដេញតាម និងដាក់ទោសដល់មនុស្សទាំងឡាយដែលបានមើលងាយដល់ពួកគេ ។

## ការប្រឈមមុខគ្នារាលដាលកាន់តែធំឡើង

ដោយសារពួកបរិសុទ្ធទាំងនេះមិនបានដោះស្រាយនូវជម្លោះរបស់ពួកគេជាមួយនឹងពួកជនអន្តោប្រវេសន៍តាមរបៀបរបស់ព្រះអម្ចាស់ នោះស្ថានការណ៍នេះបានក្លាយទៅជាកាន់តែធ្ងន់ទៅៗ ។ អ៊ីសាក ហេត ជាអភិបាលក្រុងសេដា ជាវរសេនីយត្រីជីវពល និងជាប្រធានស្ដេក បានស្នើសុំការអនុញ្ញាតពីមេបញ្ជាការជីវពល ដែលបានរស់នៅក្បែរផារ៉ូវ៉ាន់ ឲ្យកោះហៅជីវពលឲ្យជួយបង្ក្រាបពួកអ្នកមើលងាយពីក្រុមរទេះ ។ មេបញ្ជាការជីវពលឈ្មោះវិល្លាម ដេម ជាសមាជិកសាសនាចក្រម្នាក់បានប្រឹក្សានឹងអ៊ីសាក ហេត កុំឲ្យខ្វល់ច្រើនពីសម្ដីគម្រាមរបស់ពួកជនអន្តោប្រវេសន៍នោះធ្វើអ្វី ។ ជាជាងស្ដាប់តាមការប្រឹក្សានេះ អ៊ីសាក ហេត និងអ្នកដឹកនាំទីក្រុងសេដាផ្សេងទៀតបានសម្រេចចិត្តទៅបញ្ចុះបញ្ចូលពួកឥណ្ឌាសាសន៍អាមេរិកាំងដើមក្នុងតំបន់ខ្លះឲ្យវាយប្រហារក្រុមរទេះ និងទៅលួចគោរបស់ពួកគេ ដើម្បីជារបៀបមួយក្នុងការដាក់ទោសដល់ពួកជនអន្តោប្រវេសន៍នោះ ។ អ៊ីសាក ហេត បានសុំឲ្យចន ឌី លី ជាសមាជិកសាសនាចក្រក្នុងតំបន់ម្នាក់ និងជាវរសេនីយ៍ត្រី ដឹកនាំការវាយលុកនេះ ហើយបុរសទាំងពីររូបនេះបានគ្រោងដើម្បីទម្លាក់កំហុសលើពួកឥណ្ឌាសាសន៍អាមេរិកាំងដើមចំពោះទង្វើនេះ ។

## ការវាយប្រហារលើជនអន្តោប្រវេសន៍

អ៊ីសាក ហេត បានបង្ហាញគម្រោងវាយលុកក្រុមរទេះនេះដល់ក្រុមប្រឹក្សាអ្នកដឹកនាំក្នុងតំបន់នៅក្នុងសាសនាចក្រ សហគមន៍ និងជីវពល ។ សមាជិកក្រុមប្រឹក្សាខ្លះបានមិនយល់ព្រមយ៉ាងដាច់អហង្ការចំពោះគម្រោងនេះ ហើយបានសួរ ហេត ថាតើលោកបានប្រឹក្សាជាមួយនឹងប្រធាន ព្រិកហាំ យ៉ង់ អំពីបញ្ហានេះហើយឬនៅ ។ ដោយបាននិយាយថា លោកមិនទាន់បានសួរនៅឡើយ លោកហេត ក៏បានយល់ព្រមបញ្ជូនសារទូតម្នាក់ គឺលោកជេម ហេសឡែមទៅកាន់ទីក្រុងសលត៍ លេក អមដោយសំបុត្រមួយច្បាប់ពន្យល់ពីស្ថានការណ៍ និងសួរថាត្រូវតែធ្វើអ្វី ។ ទោះជាយ៉ាងណាក្ដី ដោយសារទីក្រុងសលត៍ លេក មានរយៈចម្ងាយប្រហែល ២៥០ ម៉ាយល៍ ( ៤០០ គីឡូម៉ែត្រ ) ពីទីក្រុងសេដា វាត្រូវការប្រហែលជាមួយសប្ដាហ៍ក្នុងការជិះសេះយ៉ាងលឿនដើម្បីទៅដល់ទីក្រុងសលត៍ លេក និងត្រឡប់មកទីក្រុងសេដាវិញដោយមានដំបូន្មានពីប្រធាន យ៉ង់ ជាមួយនឹងសារទូតនោះ ។

មុននេះបន្តិច មុនពេលអ៊ីសាក ហេត បានបញ្ជូនសាររបស់លោកជាមួយនឹងសារទូត ចន ឌី លី និងពួកឥណ្ឌាសាសន៍អាមេរិកាំងដើមមួយក្រុមបានវាយលុកជុំវុំក្រុមជនអន្តោប្រវេសន៍នៅកន្លែងមួយដែលហៅថា ភ្នំម៉េដូ ។ លី បានដឹកនាំការវាយលុកនេះ ប៉ុន្តែបានលាក់អត្តសញ្ញាណរបស់លោក ដើម្បីឲ្យវាមើលទៅមានតែពួកឥណ្ឌាសាសន៍អាមេរិកាំងដើមប៉ុណ្ណោះដែលបានពាក់ព័ន្ធក្នុងរឿងនេះ ។ ជនអន្តោប្រវេសន៍ខ្លះត្រូវបានគេសម្លាប់ ឬរងរបួស ហើយអ្នកនៅសេសសល់បានបណ្ដេញពួកអ្នកវាយលុកពួកគេ ដោយបង្ខំលី និងពួកឥណ្ឌាសាសន៍អាមេរិកាំងដើមឲ្យដកថយ ។ ជនអន្តោប្រវេសន៍បានទាញរទេះរបស់ខ្លួនជារង្វង់ ឬក្រោលមួយយ៉ាងមាំភ្លាមៗដើម្បីការពារខ្លួន ។ ការវាយលុកពីរដងទៀតបានកើតឡើង អំឡុងពេលការឡោមព័ទ្ធក្រុមរទេះបានប្រាំថ្ងៃ ។

នៅពេលមួយ ពួកជីវពលទីក្រុងសេដាបានដឹងថាមានជនអន្តោប្រវេសន៍ពីរនាក់បានចេញពីក្រោលរទេះនោះ ។ ពួកជីវពលបានបាញ់ពួកគេ ដោយបានសម្លាប់គេម្នាក់ ។ បុរសម្នាក់ទៀតបានរត់គេចផុត ហើយបាននាំដំណឹងនេះទៅដល់ជំរុំរទេះថា មានបុរសស្បែកសពាក់ព័ន្ធនឹងការវាយលុកប្រឆាំងនឹងពួកគេ ។ ឥឡូវនេះ អស់អ្នកដែលបានគ្រោងការវាយប្រហារនេះត្រូវបានគេចាប់កលល្បិចរបស់ខ្លួនបាន ។ ប្រសិនបើជនអន្តោប្រវេសន៍ត្រូវបានអនុញ្ញាតឲ្យបន្តធ្វើដំណើរទៅរដ្ឋកាលីហ្វ័រញ៉ា នោះដំណឹងនេះនឹងរាលដាលថា ពួកបរិសុទ្ធថ្ងៃចុងក្រោយបានទាក់ទងនឹងការវាយប្រហារលើពួកក្រុមរទេះនេះ ។ ពួកអ្នករួមគំនិតក្បត់ បានខ្លាចថាដំណឹងនេះនឹងនាំឲ្យមានលទ្ធផលអវិជ្ជមានមកដល់ខ្លួនគេ និងប្រជាជនរបស់ពួកគេ ។

### ការសម្លាប់រង្គាលនៅភ្នំម៉េដូ

នៅក្នុងបំណងដើម្បីរារាំងដំណឹងនេះកុំឲ្យរាលដាលថា ពួកបរិសុទ្ធថ្ងៃចុងក្រោយបានចូលរួមនៅក្នុងការវាយប្រហារលើក្រុមរទេះនេះ នោះអ៊ីសាក ហេត, ចន ឌី លី និងអ្នកដឹកនាំសាសនាចក្រក្នុងតំបន់ និងក្រុមជីវពលបានបង្កើតគម្រោងមួយដើម្បីសម្លាប់អ្នកនៅរស់ទាំងអស់ លើកលែងតែកូនក្មេងតូចៗប៉ុណ្ណោះ ។ ក្នុងការអនុម័តគម្រោងការនេះ ចន ឌី លី បានទៅដល់ពួកជនអន្តោប្រវេសន៍ ហើយបាននិយាយថា ពួកជីវពលនឹងការពារពួកគេកុំឲ្យរងការវាយប្រហារផ្សេងទៀត ដោយនឹងជួយនាំពួកគេត្រឡប់ទៅកាន់ទីក្រុងសេដាវិញឲ្យមានសុវត្ថិភាព ។ នៅពេលពួកជនអន្តោប្រវេសន៍បានដើរទៅកាន់ទីក្រុងសេដា ពួកជីវពលបានត្រឡប់ក្រោយ និងបានបាញ់ពួកគេ ។ ពួកឥណ្ឌាសាសន៍អាមេរិកាំងដើមខ្លះដែលបានចូលរួមនឹងពួកប្រជាជននោះបានរត់ចេញពីកន្លែងលាក់ខ្លួនមកដើម្បីជួយបាញ់បន្ថែម ។ មានជនអន្តោប្រវេសន៍ប្រហែល ១៤០ នាក់ដែលបានចូលរួមនៅក្នុងក្រុមរទេះនេះ តែមានតែកូនក្មេង ១៧ នាក់ប៉ុណ្ណោះដែលនៅរស់ ។

ពីរថ្ងៃបន្ទាប់ពីការសម្លាប់រង្គាលនោះ ជេម ហេលឡេម បានមកដល់ទីក្រុងសេដាដោយមានសារឆ្លើយតបរបស់ប្រធាន យ៉ង់ មកផង ដែលបានណែនាំឲ្យពួកអ្នកដឹកនាំក្នុងតំបន់ឲ្យអនុញ្ញាតឲ្យក្រុមរទេះនោះធ្វើដំណើរបន្តទៀតដោយមានសន្តិភាព ។ « នៅពេលហេត បានអានពាក្យរបស់ប្រធាន យ៉ង់ លោកបានយំដូចជាកូនក្មេងម្នាក់ ហើយអាចនិយាយចេញតែពាក្យ ‹ យឺតពេលហើយ យឺតពេលហើយ › » ( Richard E. Turley Jr., « The Mountain Meadows Massacre » *Ensign,* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ២០ ) ។

### លទ្ធផលដ៏សោកសៅទាំងឡាយ

ការសម្លាប់រង្គាលនៅភ្នំម៉េដូ មិនត្រឹមតែបន្សល់ទុកនូវការស្លាប់របស់ជនរងគ្រោះប្រហែល ១២០ នាក់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបណ្ដាលឲ្យមានការរងទុក្ខជាខ្លាំងផងដែរចំពោះកូនក្មេងដែលនៅរស់ និងសាច់ញាតិផ្សេងទៀតរបស់ជនរងគ្រោះទាំងនោះ ។ ពួកបរិសុទ្ធថ្ងៃចុងក្រោយខ្លះបានទទួលយក និងបានថែទាំដល់កូនក្មេងនៃជនអន្តោប្រវេសន៍ដែលបាននៅរស់ពីការសម្លាប់រង្គាលនោះ ។ នៅក្នុងឆ្នាំ ១៨៥៩ ពួកមន្ត្រីសហព័ន្ធបានទទួលសិទ្ធិអាណាព្យាបាលលើកូនក្មេងទាំងនេះ ហើយបានបញ្ជូនពួកគេត្រឡប់ទៅរកសាច់ញាតិរបស់គេនៅក្នុងរដ្ឋអាកាន់សាស ។ ពួកឥណ្ឌាសាសន៍អាមេរិកាំងដើមឈ្មោះផៃយូតក៏បានរងនូវការស្ដីបន្ទោសដ៏អយុត្តិធម៌ចំពោះបទឧក្រិដ្ឋកម្មនេះ ។

### អ្នកដឹកនាំសាសនាចក្របានដឹងពីការសម្លាប់រង្គាលនេះ

« ទោះបីជាព្រិកហាំ យ៉ង់ និងអ្នកដឹកនាំសាសនាចក្រផ្សេងទៀតនៅក្នុងទីក្រុងសលត៍លេក បានដឹងពីការសម្លាប់រង្គាលនេះភ្លាមៗបន្ទាប់ពីវាបានកើតឡើងក្ដី ក៏ការយល់ដឹងរបស់ពួកលោកអំពីទំហំនៃការពាក់ព័ន្ធរបស់ប្រជាជន និងព័ត៌មានលម្អិតដ៏អាក្រក់នៃបទល្មើសនេះបានមកបន្តិចម្ដងៗក្នុងអំឡុងពេលដ៏យូរ ។ នៅក្នុងឆ្នាំ ១៨៥៩ ពួកលោកបានដោះលែងការហៅរបស់ពួកគេដែលមាន ប្រធាន អ៊ីសាក ហេត និងអ្នកដឹកនាំសាសនាចក្រដែលមានតំណែងខ្ពស់ផ្សេងទៀតនៅក្នុងទីក្រុងសេដា ដែលបានរួមដៃនៅក្នុងការសម្លាប់រង្គាលនោះ ។ នៅក្នុងឆ្នាំ ១៨៧០ ពួកលោកបានកាត់កាលអ៊ីសាក ហេត និងចន ឌី លី ចេញពីសាសនាចក្រ ។

« នៅក្នុងឆ្នាំ ១៨៧៤ ក្រុមចៅក្រមដ៏ធំនៃដែនដី បានដាក់ទោសបុរសចំនួនប្រាំបួនរូបចំពោះការរួមដៃរបស់ពួកគេនៅក្នុងការសម្លាប់រង្គាលនោះ ។ នៅទីបញ្ចប់ ពួកគេភាគច្រើនត្រូវបានគេចាប់ខ្លួនទោះបីជាមានតែលី ដែលត្រូវបានគេចោទប្រកាន់ កាត់ទោស និងផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋនេះក្ដី ។ បុរសដែលត្រូវបានតុលាការដាក់ទោសផ្សេងទៀតបានដាក់ជូននូវភស្ដុតាងរបស់រដ្ឋ [ បានសារភាពដោយស្ម័គ្រចិត្ត និងបានដាក់ជូននូវភស្ដុតាងប្រឆាំងនឹងកូនក្ដីផ្សេងទៀត ] ហើយអ្នកផ្សេងទៀតបានចំណាយពេលជាច្រើនឆ្នាំរត់គេចពីប្រព័ន្ធច្បាប់ ។ ពួកជីវពលផ្សេងទៀតដែលសម្លាប់យ៉ាងរង្គាលនេះ បានរស់នៅក្នុងជីវិតមួយនៅក្រោមអារម្មណ៍ជាប់ទោសដ៏អាប់អួរ និងបានមានបទពិសោធន៍យ៉ាងអាក្រក់ចំពោះអ្វីដែលពួកគេធ្វើ និងបានឃើញ » ( Richard E. Turley Jr., « The Mountain Meadows Massacre » *Ensign,* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ២០ ) ។

### ខួបរំឭកលើកទី ១៥០ នៃការសម្លាប់រង្គាលនៅភ្នំម៉េដូ

ប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយបានមានប្រសាសន៍ ៖

« ទំនួលខុសត្រូវចំពោះ [ ការសម្លាប់រង្គាលនៅភ្នំម៉េដូ ] មានដល់អ្នកដឹកនាំក្នុងតំបន់នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ នៅក្នុងតំបន់ក្បែរភ្នំម៉េដូ ដែលបានកាន់តំណែងស៊ីវិល និងទាហាន និងលើពួកសមាជិកនៃសាសនាចក្រដែលធ្វើការនៅក្នុងការដឹកនាំរបស់ពួកគេ ។ . . .

« . . . ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែល យើងប្រកាន់ ស្អប់ការសម្លាប់ដ៏ឃោរឃៅដល់បុរស ស្ត្រី និងកូនក្មេង ។ តាមពិត វាបានគាំទ្រដល់សេចក្ដីសុខសាន្ត និង ការអភ័យទោស ។ អ្វីបានកើតឡើង [ នៅឯភ្នំម៉េដូ ] ជាយូរកន្លងមក ដោយការប្រព្រឹត្តរបស់ពួកសមាជិកនៃសាសនាចក្ររបស់យើង តំណាងឲ្យការដើរលើផ្លូវខុសដ៏ខ្លាំង និងមិនអាចដោះសារបានលើការបង្រៀន និងការដឹកនាំរបស់ពួកគ្រីស្ទាន ។ . . . គ្មានការសង្ស័យនៃភាពយុត្តិធម៌នៃស្ថានសួគ៌ណា នឹងអាចដាក់លើការផ្ដន្ទាទោសដ៏ត្រឹមត្រូវចំពោះអស់អ្នកដែលត្រូវទទួលខុសត្រូវចំពោះការសម្លាប់រង្គាលនេះបានឡើយ ។ . . .

« . . . សូមឲ្យព្រះដែលគង់នៅលើស្ថានសួគ៌ ប្រទានពរដល់យើងរាល់គ្នា ដែលជាបុត្រា និងបុត្រីទ្រង់ ដើម្បីផ្ដល់កិត្តិយសដល់អស់អ្នកដែលបានស្លាប់នៅទីនេះ ដោយការបង្ហាញដល់គ្នាទៅវិញទៅមកនូវសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធ និងវិញ្ញាណនៃការអភ័យទោសដែលព្រះរាជបុត្រាបង្កើតតែមួយគត់របស់ទ្រង់បានធ្វើបដិរូបកម្ម » ( « 150th Anniversary of Mountain Meadows Massacre » ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៧ នៅគេហទំព័រ mormonnewsroom.org/article/150th-anniversary-of-mountain-meadows-massacre ) ។

© ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។

សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ថ្នាក់ទីវិទ្យាស្ថានសាសនា